***

## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ៦៦ សសរ

ស្តីពី

ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់
បទល្មើសព្រៃឈើ និងបទល្មើសនៃការបរបាញ់សម្លាប់សត្វព្រៃនៅតំបន់ភាគខាងលិច
នៃខេត្តកោះកុង ខេត្តពោធិសាត់ និងខេត្តបាត់ដំបង

* * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

Compiled by EWMI-Cambodia
"Safeguarding Cambodians' Land Rights Project"
supported by US Department of State (04/09)

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញសេចក្តីប្រកាសលេខ ០១/ប្រក ចុះថ្ងៃទី២៥ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីវិធានគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ

-យោងតាមការងារចាំបាច់ របស់រាជរដ្ឋាភិបាល

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់ជាបន្ទាន់នូវបទល្មើស ព្រៃឈើ និងបទល្មើសនៃការបរបាញ់សម្លាប់សត្វព្រៃនៅភូមិភាគខាងលិចនៃខេត្តកោះកុង ពោធិសាត់ និង បាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម នាយឧត្តមសេនីយ ទៀ បាញ់ | សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | ជាប្រធាន |
| ២-ឯកឧត្តម យុន ឃាំង | រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | អនុប្រធាន |
| ៣-ឯកឧត្តម នាយឧត្តមសេនីយ កែ គឹមយ៉ាន | អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| ៤-ឯកឧត្តម ឧត្តមសេនីយឯក ហុក ឡុងឌី | អគ្គនាយកនគរបាលជាតិ | សមាជិក |
| ៥-ឯកឧត្តម ឧត្តមសេនីយឯក ម៉ុល សារឿន | អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ នៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៦-ឯកឧត្តម ឧត្តមសេនីយឯក មាស សុផា | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ៧-ឯកឧត្តម ឧត្តមសេនីយឯក សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៨-ឯកឧត្តម ច័ន្ទ សុខអ៊ីច | រដ្ឋលេខាធិការក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩-ឯកឧត្តម ឆាន់ សាផាន | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១០-ឯកឧត្តម ខូច ជេងហ៊ាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១១-ឯកឧត្តម អង្គ វង្សវឌ្ឍនា | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១២-ឯកឧត្តម ឡុង វិសាលោ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

១៣-ឯកឧត្តម ស៊ាន វិសុទ្ធ សមាជិកអចិន្ត្រៃយ៍អង្គភាពប្រឆាំងអំពើពុករលួយ សមាជិក

១៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុំ សំខាន់ មេបញ្ជាការកងទ័ពជើងទឹក សមាជិក

ប្រការ ២ : គណៈកម្មការចំរុះអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ ៖

-ចុះស្រាវជ្រាវ និងត្រួតពិនិត្យអោយបានច្បាស់លាស់នូវរាល់បទល្មើសព្រៃឈើគ្រប់ប្រភេទ ការធ្វើអាជីវកម្មផល និងអនុផលព្រៃឈើប៉ះពាល់បរិស្ថានយ៉ាងធ្ងន់ធ្ងរ បទល្មើសនៃការជីករ៉ែ ត្បូង និងបទល្មើសនៃការបរបាញ់សម្លាប់សត្វព្រៃ ដែលបង្កឡើងដោយក្រុមជននិងឈ្មួញអក់ធួន ដើម្បីបង្ការទប់ស្កាត់និរន្តរភាពព្រៃឈើ បរិស្ថាន និងសត្វព្រៃនៅក្នុងតំបន់ខាងលើ ។

-លើកវិធានការទប់ស្កាត់ និងបង្ក្រាបជាបន្ទាន់តាមផ្លូវច្បាប់នូវរាល់បទល្មើសខាងលើ អោយមានប្រសិទ្ធភាពនិងស្រាវជ្រាវរកអោយឃើញនូវបុគ្គលដែលបានប្រព្រឹត្តបទល្មើស និងមុខសញ្ញាដែលមានការពាក់ព័ន្ធ ដើម្បីបញ្ជូនខ្លួនទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់ជាធរមាន ។

-ធ្វើការចរចាជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រថៃ ដើម្បីរកដំណោះស្រាយសមស្របក្នុងកិច្ចសហការទប់ស្កាត់ និង បង្ក្រាបរាល់បទល្មើសខាងលើ ។

-ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលអំពីលទ្ធផលការងារដែលអនុវត្តបាន និងសុំយោបល់ណែនាំពីរាជរដ្ឋាភិបាល ក្នុងករណីចាំបាច់ ។

ប្រការ ៣ : គណៈកម្មការចំរុះអន្តរក្រសួង មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាជំនួយការងារដែលមានសមាសភាព ដូចខាងក្រោម ៖

-ឯកឧត្តម ចន្ទ សារុន អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ជាប្រធាន

-ឯកឧត្តម ឧត្តមសេនីយឯក មល់ រឿប ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី និងជានាយរងសេនាធិការចំរុះកងយោធពលខេមរភូមិន្ទ សមាជិក

-ឯកឧត្តម ឧត្តមសេនីយឯក យូ ស៊ិនឡុង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក

-ឯកឧត្តម ឧត្តមសេនីយឯក ជា តារា នាយកទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក

-លោក ជុំ ច័ន្ទតារា នាយកលេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាល សមាជិក

-លោក អ៊ុំ អូ ប្រធានការិយាល័យនីតិកម្ម និងវិវាទនៃនាយកដ្ឋានរុក្ខាប្រមាញ់ និងនេសាទ សមាជិក

ទីតាំងនៃលេខាធិការដ្ឋាន គឺអាស្រ័យដោយឯកឧត្តមប្រធានគណៈកម្មការចំរុះអន្តរក្រសួង ធ្វើការកំណត់តាមការជាក់ស្តែង ។

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

ប្រការ ៤ : គណៈកម្មការចំរុះអន្តរក្រសួង មានសិទ្ធិប្រើត្រារបស់ក្រសួងការពារជាតិ ដើម្បីសំរួលការងារ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងអាណាព្យាបាលផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គមេបញ្ជាការកងយោធពល ខេមរភូមិន្ទ អភិបាលខេត្តកោះកុង អភិបាលខេត្តពោធិ៍សាត់ អភិបាលខេត្តបាត់ដំបង រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចចែងក្នុងប្រការ១ និងប្រការ៣ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)